**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ: ១២១២ អ.ក
ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១
ជំនុំជម្រះលេខ៖ ១៦៥២ ជ.វ
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១
សាលក្រមលេខ: ៣៤ (ប)
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាល
**នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ដោយមានសមាសភាព៖**

*ក្រុមប្រឹក្សាជំនុំជម្រះ*

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា
លោកស្រី ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា
លោក ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

*តំណាងអយ្យការ*

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

*ក្រឡាបញ្ជីសវនាការ*

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

**លើសំណុំរឿងព្រហ្មទណ្ឌលេខ: ១២១២ អ.ក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ដែលមាន៖**

ជនជាប់ចោទឈ្មោះ [redacted] **ចាន់ឆាត** ហៅ **ពៅ** ភេទប្រុស អាយុ ៤៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីលំនៅកំណើតនៅ [redacted] រាជធានីភ្នំពេញ និងទីកន្លែងមុនពេលឃាត់ខ្លួននៅភូមិលៀក ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សេង (ស្លាប់) ម្ដាយឈ្មោះ [redacted] ម៉ាលី(ស្លាប់) ពោះម៉ាយ មានកូន២នាក់ ទោសពីមុនគ្មាន។

**(ឃាត់ខ្លួននៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ និងឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:២៨៣៧/២១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល)។**

ជាប់ចោទពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនផង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលៀក ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ **នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។**

-លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទ។

-បានឃើញ របាយការណ៍លេខ: ១៣៥/០២១ របក ចុះថ្ងៃទី២៩ខែកក្កដា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល នៃអធិការដ្ឋាននគរបាលស្រុកកណ្ដាលស្ទឹង។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៥១៩ ដក.សព ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។



Scanned with CamScanner

-បានឃើញ ដីកាដំណោះស្រាយលេខ: ១៦១៦/២១ ដក.ដស ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១៨ និង០០នាទី នៅចំណុចភូមិឈៀក ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] ចាន់ឆាត ហៅពៅ ភេទប្រុស ទូរស័ព្ទទៅឈ្មោះ និត ភេទប្រុស រស់នៅឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល តាមរយ:ទូរស័ព្ទលេខ ០១៦ ៤៧៤ ១៩៩ (ជាអ្នកលក់ថ្នាំញៀន) កម្ម៉ង់ទិញថ្នាំញៀន ក្នុងតម្លៃ ៦៥០,០០០(ហុកសិបប្រាំម៉ឺន)រៀល បន្តិចក្រោយមកឈ្មោះ និត បានឱ្យជនមិនស្គាល់អត្តសញ្ញាណ(កូនចៅ) យកថ្នាំញៀន០១កញ្ចប់ធំ ទៅប្រគល់ឱ្យឈ្មោះ [redacted] ចាន់ឆាត ដល់ផ្ទះ។ ពេលបានថ្នាំញៀនហើយជនជាប់ចោទឈ្មោះ [redacted] ចាន់ឆាត បានវែលែកថ្នាំញៀនជាកញ្ចប់តូចលក់ក្នុងតម្លៃ២០,០០០(ពីរ)ម៉ឺនរៀល លក់បានប្រហែលជាប្រាំកញ្ចប់។ លុះដល់ម៉ោងប្រហែល២២យប់ ថ្ងៃខែឆ្នាំដដែល ខណ:ពេលដែលអ្នកទិញចុងក្រោយបានចាកចេញពីផ្ទះរបស់ជនជាប់ចោទក៏ត្រូវបានសមត្ថកិច្ចនគរបាលសម្រុកចូលបង្ក្រាបជនជាប់ចោទដោយបានឃាត់ខ្លួន និងឆែកឆេរចាប់បានម្រៅក្រាមពណ៌សសង្ស័យជាថ្នាំញៀនចំនួន ២៤កញ្ចប់ ទម្ងន់ ៤,៥៦(បួនក្បៀសហាសិបប្រាំ)ក្រាម រួចនាំជនជាប់ចោទទៅសាកសួរ និងធ្វើតេស្តទឹកនោម ជាលទ្ធផលវិជ្ជមាន មានផ្ទុកសារធាតុញៀនក្នុងខ្លួន។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ចាន់ឆាត** បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ សមត្ថកិច្ចបានដកហូតគ្រឿងញៀនចំនួន ២៤កញ្ចប់ ប្រភេទម៉ាទឹកកក។ គ្រឿងញៀននេះ ខ្លួនទិញពីឈ្មោះ និត ក្នុង ០១កញ្ចប់ តម្លៃ ១ម៉ឺនរៀល។ គ្រឿងញៀននេះ ខ្លួនយកមកប្រើប្រាស់ខ្លះ និងទុកលក់បន្តខ្លះ ដោយក្នុង ០១កញ្ចប់ តម្លៃ ០២ម៉ឺនរៀល។ ខ្លួនជួញដូរគ្រឿងញៀនបាន ៥ដងហើយ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយ:ពេល ០៥ខែ ដោយក្នុង ០១ថ្ងៃ ខ្លួនជក់អស់ ០១កញ្ចប់។ ខ្លួនលក់គ្រឿងញៀនប្រហែល ៤-៥ខែមកហើយ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ នាពេលសវនាការនេះ ជនជាប់ចោទឈ្មោះ [redacted] **ចាន់ឆាត** ហៅ **ពៅ** បានសារភាពថា ពិតជាបានជួញដូរ និងប្រើប្រាស់គ្រឿងញៀនប្រាកដមែន។ ជនជាប់ចោទបានទិញគ្រឿងញៀនប្រហែល ៤-៥ខែមកហើយ ដើម្បីលក់បន្ត ដោយក្នុង ០១កញ្ចប់ តម្លៃ ២ម៉ឺនរៀល។ នៅពេលឃាត់ខ្លួន សមត្ថកិច្ចបានដកហូតគ្រឿងញៀនចំនួន ២៧កញ្ចប់ ទម្ងន់ ៤,៥៦ក្រាម ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ទុកដដែល ជូនតុលាការសម្រេចតាមច្បាប់កំណត់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ឆាត** ហៅ **ពៅ** ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចតំណាងអយ្យការបានចោទប្រកាន់ប្រាកដមែន ដូច្នេះស្នើសុំបន្ធូរបន្ថយទោស ដើម្បីឱ្យជនជាប់ចោទកែប្រែខ្លួនសារជាថ្មី។

+សម្តីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំសម្រាលទោស។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីកាពារសិទ្ធិឱ្យជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ឯកសារ ភស្តុតាង

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១.តុលាការទទួលសំណុំរឿងព្រហ្មទណ្ឌ ពីចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទឈ្មោះ [redacted] **ចាន់ណាត** ហៅ **ពៅ** ភេទប្រុស អាយុ ៤៩ឆ្នាំ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ៖ ១៦១៦ ដក.ជវ/២១ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ តុលាការធ្វើការជំនុំជម្រះលើជនជាប់ចោទយោងតាមមាត្រា ២៨៩ ,មាត្រា ២៩១ និងមាត្រា ៣៤៨ នៃ**ក្រមនីតិវិធីព្រហ្មទណ្ឌ**។

២.ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ,របាយការណ៍សមត្ថកិច្ច ព្រមទាំងភស្តុតាង ឃើញថា នៅថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] ចាន់ណាត ពិតជាបានទិញគ្រឿងញៀនពីឈ្មោះ និត ចំនួន ២៤កញ្ចប់ ទម្ងន់ ៤,៥៦ក្រាម ដើម្បីយកមកប្រើប្រាស់ខ្លះ និងលក់បន្តខ្លះ ដោយក្នុង ០១កញ្ចប់ លក់តម្លៃ ០២ម៉ឺនរៀល។ តែជនជាប់ចោទរូបនេះធ្លាប់ជួញដូរគ្រឿងញៀនច្រើនដងមកហើយ។ អំពើរបស់ជនជាប់ចោទ គឺជាអង្គហេតុត្រូវ នឹងធាតុផ្សំបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលមានចែងតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ នៃ**ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

៣.តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល អធិការដ្ឋាននគរបាលស្រុកកណ្តាលស្ទឹង ផ្នែកនគរបាលប្រឆាំងគ្រឿងញៀន ឃើញមានម្សៅក្រាមសថ្លាចំនួន ២៤ កញ្ចប់ ស្មើទម្ងន់ ៤,៥៦ក្រាម ជាប្រភេទមេតំហ្វេតាមីន ចំណុចនេះបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

៤.ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណាត** ហៅ **ពៅ** ជានីតិជន មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវបទព្រហ្មទណ្ឌនូវទង្វើរបស់ខ្លួន។

៥.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **ចាន់ណាត** ហៅ **ពៅ** ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ហើយសុំតម្កល់បទចោទប្រកាន់នេះទុកដដែលនោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

៦.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖ ស្នើសុំសម្រាលទោសដល់ជនជាប់ចោទ ចំណុចនេះតុលាការនឹងពិនិត្យពិចារណា។

៧.មានភស្តុងតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ចាន់ណាត** ហៅ **ពៅ** ភេទប្រុស អាយុ ៤៩ឆ្នាំ ពីបទ៖**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនដង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលៀប ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០២១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ នៃ**ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។



Scanned with CamScanner

៨.អំពើជនជាប់ចោទឈ្មោះ [redacted] **ចាន់ឆាត** ហៅ **ពៅ** បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរាបរយសាធារណៈ និងសន្តិសុខសង្គម ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ ដូច្នេះទណ្ឌកម្ម ដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិចារណា។

៩.វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល មាន៖ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន ២៤កញ្ចប់ និងមធ្យម ០១កញ្ចប់ វេចខ្ចប់ដាក់ស្រោមសំបុត្រធំពណ៌សចំនួនពីរបិតជិតគ្មានលេខកូដ ,ផង់វេចខ្ចប់ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន ជាវត្ថុខុសច្បាប់ គប្បីរឹបអូស។ រីឯទូរស័ព្ទដៃចំនួនមួយគ្រឿង ម៉ាក SUMSUNG ពណ៌ស ជាមធ្យោបាយទំនាក់ទំនងក្នុងការប្រព្រឹត្តបទល្មើស គប្បីរឹបអូស។

## <u>**ហេតុដូច្នេះសម្រេច**</u>

១/-ផ្តន្ទាទោសលើឈ្មោះ [redacted] **ចាន់ឆាត** ហៅ **ពៅ** ភេទប្រុស អាយុ ៤៩ឆ្នាំ ដាក់ពន្ធនាគារក្នុងកំណត់រយៈពេល ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនច្រើនផង និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលៀប ឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន**។

២/-រឹបអូសវត្ថុតាងចាប់យកតាមកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល មាន៖ ម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន ២៤កញ្ចប់ និងមធ្យម ០១កញ្ចប់ វេចខ្ចប់ដាក់ស្រោមសំបុត្រធំពណ៌សចំនួនពីរបិតជិតគ្មានលេខកូដ ,ផង់វេចខ្ចប់ និងសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន និងទូរស័ព្ទដៃចំនួនមួយគ្រឿង ម៉ាក SUMSUNG ពណ៌ស។

សាលក្រមនេះជំនុំជម្រះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ,ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខ និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃច័ន្ទ ១២ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តកណ្តាល ,ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]